# ពាក្យស្នើសុំធ្វើកម្មសិក្សា

***ធនាគារ អេស៊ីលីដា ភីអិលស៊ី*** *ជាធនាគារពាណិជ្ជនាំមុខក្នុងប្រទេសកម្ពុជា ក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុល្អបំផុត ជូនដល់សាធារណជនគ្រប់មជ្ឈដ្ឋាន ក្នុងសហគមន៍ ។ ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារមួយ ដែលបានផ្តល់ចំណេះដឹងបទពិសោធន៍ការងារជាក់ស្តែង ដល់និស្សិតទាំងក្នុង និងក្រៅប្រទេស ដោយមិនប្រកាន់ពូជសាសន៍, សាសនា, ពណ៌សម្បុរ, ភេទ ឬជាតិកំណើតឡើយ ។*

*សម្គាល់: - ពាក្យស្នើសុំចុះកម្មសិក្សា អាចទាញយកពីគេហទំព័រធនាគារ អេស៊ីលីដា ភីអិលស៊ី www.acledabank.com.kh ។*

*- រាល់ការទទួលពាក្យស្នើសុំរបស់និស្សិត មិនមានន័យថានិស្សិតត្រូវបានអនុញ្ញាតឲ្យចុះកម្មសិក្សាជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី នោះទេ ។*

## ព័ត៌មានជាមូលដ្ឋាន

តើលោក-អ្នកធ្លាប់មកធ្វើកម្មសិក្សា នៅធនាគារ អេស៊ីលីដា ភីអិលស៊ី ដែរ ឬទេ ? (សូមគូសជម្រើសមួយ) ☐ មិនធ្លាប់, ☐ធ្លាប់, បើធ្លាប់ សូមបញ្ជាក់ឲ្យបានច្បាស់លាស់នូវចំណុចខាងក្រោម ៖

កាលបរិច្ឆេទ : ..........

ប្រធានបទ : ..........

នៅសាខា / ការិយាល័យ / នាយកដ្ឋាន : ..........

ចំនួននិស្សិតចុះកម្មសិក្សា : ............ នាក់

គោលបំណងនៃការមកចុះកម្មសិក្សា : ☐ សរសេរសារណា ☐ សរសេររបាយការណ៍ ☐ ផ្សេងៗ (សូមបញ្ជាក់) ..........

ប្រធានបទ : .......... ភាសាអង់គ្លេស..........

នៅសាខា / ការិយាល័យ / នាយកដ្ឋាន : ..........

ពេលវេលានៃការស្នើសុំចុះកម្មសិក្សា

☐ ចាប់ពីម៉ោង ៧:៣០ នាទីព្រឹក ដល់ម៉ោង ១២:០០ នាទីថ្ងៃត្រង់,

☐ ចាប់ពីម៉ោង ១:០០ នាទីរសៀល ដល់ម៉ោង ៤:៣០ នាទីរសៀល

☐ ផ្សេងៗ ..........

កាលបរិច្ឆេទចុះកម្មសិក្សា ចាប់ពីថ្ងៃទី ...... ខែ ........ ឆ្នាំ ........ ដល់ថ្ងៃទី ........ ខែ ........ ឆ្នាំ ..........

## ព័ត៌មានផ្ទាល់ខ្លួន

គោត្តនាម និងនាម .......... ជាអក្សរឡាតាំង .......... ភេទ..........

ថ្ងៃខែឆ្នាំកំណើត .......... ទីកន្លែងកំណើត (សូមសរសេរតែឈ្មោះខេត្ត ឬក្រុងតែប៉ុណ្ណោះ) ..........

ជនជាតិ .......... សញ្ជាតិ ..........ស្ថានភាពគ្រួសារ : ☐ នៅលីវ ☐ រៀបការ ☐ ផ្សេងៗ ..........

លេខទូរសព្ទផ្ទាល់ខ្លួន ☎ : ..........

រូបថតថ្មី
ទំហំ 4x6
(មិនឲ្យយូរជាង ០៣ខែ)

កម្រិតវប្បធម៌ : .......... ឆ្នាំទី : .......... ជំនាញ : ..........

ឈ្មោះគ្រឹះស្ថានសិក្សា : ..........

អាសយដ្ឋានអចិន្ត្រៃយ៍: (យកតាមសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ)

..........

បទពិសោធន៍ការងារ : (សូមគូសជម្រើសមួយ) ☐ គ្មាន ☐ មាន (ប្រសិនបើមានសូមសរសេរនូវបទពិសោធន៍ការងារ)

- ..........
- ..........
- ..........

## ការធានាអះអាង

ខ្ញុំបាទ / នាងខ្ញុំសូមធានាអះអាងថា រាល់អត្ថន័យ និងឯកសារក្នុងពាក្យស្នើសុំធ្វើកម្មសិក្សានេះ ពិតជាមានលក្ខណៈត្រឹមត្រូវ គ្រប់គ្រាន់ គ្មានការក្លែងបន្លំឡើយ ។ ករណីមិនពិតដូចការអះអាងនេះ ទោះជាត្រូវបានចូលធ្វើកម្មសិក្សាជាស្ថាពរក៏ដោយ ក៏ខ្ញុំបាទ / នាងខ្ញុំ យល់ព្រមឲ្យធនាគារ អេស៊ីលីដា ភីអិលស៊ី បញ្ចប់ការចុះធ្វើកម្មសិក្សារបស់ខ្ញុំបាទ / នាងខ្ញុំ ដោយគ្មានលក្ខខណ្ឌ ។

កាលបរិច្ឆេទនៃការដាក់ពាក្យ: ......................................................

ហត្ថលេខា

ឈ្មោះ ....................................................

## ការដាក់ពាក្យ

**ក- ឯកសារដែលត្រូវភ្ជាប់មកជាមួយរួមមាន :**

១- លិខិតស្នើសុំធ្វើកម្មសិក្សាចេញដោយសាលា គោរពជូននាយក-នាយិកាប្រតិបត្តិធនធានមនុស្ស "SVP & Head of Human Resources Division" (ច្បាប់ថតចម្លង)

២- លក្ខខណ្ឌធ្វើកម្មសិក្សា (គ្រប់សមាជិកក្រុម ដែលដាក់ពាក្យត្រូវអានឲ្យយល់ និងចុះហត្ថលេខា)

៣- កម្រងសំណួរដែលត្រូវស្រាវជ្រាវទាក់ទងទៅនឹងប្រធានបទដែលស្នើសុំ (មិនឲ្យលើស ៣០ សំណួរ)

❈ *លិខិតឆ្លងដែន (ច្បាប់ថតចម្លង) មួយច្បាប់ ដែលមានសុពលភាពក្នុងអំឡុងពេលធ្វើកម្មសិក្សា (សម្រាប់និស្សិតក្រៅប្រទេស)*

**ខ- អាសយដ្ឋានទទួលពាក្យ :**

ផ្ញើតាមរយៈអ៊ីម៉ែល hr.develop@acledabank.com.kh ។

# លក្ខខណ្ឌធ្វើកម្មសិក្សា

ដើម្បីឲ្យការធ្វើកម្មសិក្សារបស់និស្សិតនៅធនាគារ អេស៊ីលីដា ភីអិលស៊ី មានប្រសិទ្ធភាព និងប្រព្រឹត្តទៅដោយរលូន កម្មសិក្សាការីត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម ៖

## ១. លក្ខខណ្ឌមុនពេលធ្វើកម្មសិក្សា

ប្រធានបទ ដែលកម្មសិក្សាការីនឹងទទួលបានក្នុងពេលតម្រង់ទិស រួមមាន ៖

ក. ប្រវត្តិ ទស្សនៈ បេសកកម្ម វប្បធម៌ការងារ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

ខ. រចនាសម្ព័ន្ធការងាររបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

គ. ផលិតផល និងសេវាកម្ម ដែលធនាគារ អេស៊ីលីដា ភីអិលស៊ី កំពុងធ្វើប្រតិបត្តិការ

ឃ. ការរៀបចំកាយ វាចា ចិត្ត ឲ្យបានល្អក្នុងទីបរិវេណ ធនាគារ អេស៊ីលីដា ភីអិលស៊ី

ង. វិធានវិន័យ សណ្តាប់ធ្នាប់ អនាម័យ ក្នុងទីបរិវេណ ធនាគារ អេស៊ីលីដា

ច. ការសិក្សាស្រាវជ្រាវ និងរក្សាបាននូវសីលធម៌ សុជីវធម៌ ក្នុងទីបរិវេណ ធនាគារ អេស៊ីលីដា ភីអិលស៊ី ។

## ២. លក្ខខណ្ឌពេលធ្វើកម្មសិក្សា

### *ក. វិន័យ និងបទបញ្ជា*

១. និស្សិតបុរស ត្រូវកាត់សក់ កោរពុកមាត់ ពុកចង្កា ឲ្យបានស្អាតបាត ។ និស្សិតនារី ត្រូវរៀបចំសក់ក្បាលឲ្យមានរបៀបរៀបរយ ។

២. និស្សិតទាំងពីរភេទ ត្រូវស្លៀកសម្លៀកបំពាក់និស្សិត អាវស ឬផ្ទៃមេឃ ដៃវែង ឬដៃខ្លី ជាមួយសំពត់បត់វែង / សំពត់ខ្លីក្រោមជង្គង់ពណ៌ខ្មៅ ឬទឹកប៊ិក (សម្រាប់នារី) និងខោជើងវែងពណ៌ខ្មៅ ឬទឹកប៊ិក (សម្រាប់បុរស) ។

៣. និស្សិតទាំងពីរភេទត្រូវពាក់កាតសម្គាល់ខ្លួន ដែលផ្តល់ដោយធនាគារ អេស៊ីលីដា ភីអិលស៊ី នៅក្នុងបរិវេណធនាគារ អេស៊ីលីដា ភីអិលស៊ី ។

៤. ប្រើវាចាពីរោះ ទឹកមុខញញឹម រាល់ការប្រាស្រ័យ ។

៥. ត្រូវគោរពវិន័យ បទបញ្ជាផ្ទៃក្នុងរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ក៏ដូចជាគោលការណ៍ និងនីតិវិធីស្តីពីការធ្វើកម្មសិក្សា ។

៦. និស្សិតទាំងពីរភេទ ត្រូវមកធ្វើកម្មសិក្សាឲ្យបានទៀងទាត់ តាមកាលវិភាគដែលបានកំណត់ ដោយធ្វើការចុះវត្តមានឲ្យបានត្រឹមត្រូវ ។ ករណីមានធុរៈឈប់សម្រាក់ ត្រូវសុំច្បាប់អនុញ្ញាតដោយជូនដំណឹងតាមរយៈសារអេឡិចត្រូនិក (E-mail, SMS ...) មកគ្រូទទួលបន្ទុក ប៉ុន្តែ **មិនអនុញ្ញាតឲ្យឈប់លើសពី ០៣ (បី) ថ្ងៃ** ឡើយ ក្នុងអំឡុងពេលធ្វើកម្មសិក្សា ។ **កម្មសិក្សាការីនឹងមិនទទួលបានលិខិតបញ្ជាក់កម្មសិក្សាឡើយ ក្នុងករណីសុំច្បាប់ឈប់សម្រាកលើសរយៈពេលកំណត់ខាងលើ ។**

### *ខ. អវត្តមានដោយគ្មានច្បាប់អនុញ្ញាត*

ករណីកម្មសិក្សាការីអវត្តមានដោយគ្មានច្បាប់អនុញ្ញាត នាយកដ្ឋានធនធានមនុស្សធនាគារ អេស៊ីលីដា ភីអិលស៊ី មានសិទ្ធិសម្រេចលុបឈ្មោះចេញពីបញ្ជីធ្វើកម្មសិក្សា និងមិនចេញលិខិតបញ្ជាក់កម្មសិក្សាជូនឡើយ ។

### *គ. ការសុំបោះបង់ចោលការធ្វើកម្មសិក្សា*

**គ.១ មុនពេលធ្វើកម្មសិក្សា**

ករណីកម្មសិក្សាការីមិនទាន់បានចុះធ្វើកម្មសិក្សា ហើយមានបំណងស្នើសុំបោះបង់ចោលការធ្វើកម្មសិក្សា កម្មសិក្សាការីត្រូវជូនដំណឹងតាមរយៈសារអេឡិចត្រូនិក (E-mail, SMS ...) ដូចខាងក្រោម ៖

- ចុះធ្វើកម្មសិក្សានៅការិយាល័យកណ្តាល ឬសាខាជុំវិញរាជធានីភ្នំពេញ ឬក្រុមហ៊ុនបុត្រសម្ព័ន្ធក្នុងប្រទេស ត្រូវជូនដំណឹងមកផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស នៃនាយកដ្ឋានធនធានមនុស្ស ឲ្យបានមុនកាលបរិច្ឆេទចុះធ្វើកម្មសិក្សា ។
- ចុះធ្វើកម្មសិក្សានៅលំដាប់សាខា ត្រូវជូនដំណឹងមករដ្ឋបាលសាខា " ក " នៃទីកន្លែងដែលសាមីស្នើសុំចុះធ្វើកម្មសិក្សា ឲ្យបានមុនកាលបរិច្ឆេទចុះធ្វើកម្មសិក្សា ។

**គ.២ ពេលធ្វើកម្មសិក្សា**

ករណីកម្មសិក្សាការីកំពុងធ្វើកម្មសិក្សា ហើយមានបំណងស្នើសុំបោះបង់ចោលការធ្វើកម្មសិក្សា កម្មសិក្សាការីត្រូវជូនដំណឹងតាមរយៈសារអេឡិចត្រូនិក (E-mail, SMS ...) មកគ្រូទទួលបន្ទុកបង្ហាត់បង្រៀនផ្ទាល់ នៃទីកន្លែងដែលសាមីចុះធ្វើកម្មសិក្សា ឲ្យបានមុនកាលបរិច្ឆេទសុំឈប់ ។

### *ឃ. ការប្រើប្រាស់ឯកសារ*

កម្មសិក្សាការី ត្រូវបានអនុញ្ញាតឲ្យធ្វើការសិក្សាស្រាវជ្រាវ តាមរយៈការអាន ឬកត់ត្រាតាមសៀវភៅគោលការណ៍ នីតិវិធី សេចក្តីណែនាំ និងឯកសារផ្សេងៗរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ឬក្រុមហ៊ុនបុត្រសម្ព័ន្ធក្នុងប្រទេសតែប៉ុណ្ណោះ (រក្សានូវអាថ៌កំបាំងវិជ្ជាជីវៈ) ។ ***ធនាគារ អេស៊ីលីដា ភីអិលស៊ី មិនអនុញ្ញាតឲ្យកម្មសិក្សាការីយកឯកសារដែលបានរៀបរាប់ខាងលើចេញពីបរិវេណធនាគារ អេស៊ីលីដា ភីអិលស៊ី / ក្រុមហ៊ុនបុត្រសម្ព័ន្ធក្នុងប្រទេស ឬធ្វើការថតចម្លង តាមរយៈទូរស័ព្ទ, កាមេរ៉ា ... បានឡើយ លើកលែងតែឯកសារសម្រាប់ផ្សព្វផ្សាយជាសាធារណៈ*** ។

## ៣. លក្ខខណ្ឌក្រោយពេលធ្វើកម្មសិក្សា

ក. ក្រោយពេលបញ្ចប់កម្មសិក្សា កម្មសិក្សាការីត្រូវប្រគល់នូវគំរូពង្រាងសៀវភៅសារណា / របាយការណ៍សង្ខេបអំពីចំណេះដឹង ដែលកម្មសិក្សាការីបានទទួល ក្នុងអំឡុងពេលធ្វើកម្មសិក្សា មកគ្រូទទួលបន្ទុកកម្មសិក្សាការី ដើម្បីវាយតម្លៃចំណេះដឹង ។

ខ. កម្មសិក្សាការីត្រូវប្រគល់សៀវភៅសារណា ឬរបាយការណ៍ ដែលការពារជាប់ជាស្ថាពរមកធនាគារ អេស៊ីលីដា ភីអិលស៊ី ចំនួន **០១** (មួយ) ក្បាល (ច្បាប់ថតចម្លង) ។

ខ្ញុំបាទ / នាងខ្ញុំ បានអាន យល់ និងសន្យាថា អនុវត្តឲ្យបានតាមលក្ខខណ្ឌដូចបានចែងខាងលើ ។

ថ្ងៃ.................... ............. ខែ .............. ឆ្នាំ ...... ........ ព.ស. ........

.................... ថ្ងៃទី......... ខែ........... ឆ្នាំ..........

**ហត្ថលេខា**

ឈ្មោះ........................